ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការ សម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការសម្រាប់ដោះស្រាយកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម អ៊ិត សំហេង | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | ប្រធាន |
| ២- | ឯកឧត្តម វង សូត | រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣- | ឯកឧត្តម នេត សាវឿន | អគ្គស្នងការនគរបាលជាតិ | អនុប្រធាន |
| ៤- | ឯកឧត្តម កែប ជុតិមា | អភិបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៥- | ឯកឧត្តម សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | អនុប្រធាន |
| ៦- | ឯកឧត្តម ហ៊ីង ប៊ុនហៀង | នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៧- | ឯកឧត្តម សុខ ចិន្តា | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨- | ឯកឧត្តម ម៉ុន សម | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៩- | ឯកឧត្តម គីម ស៊ីថន | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |

១០- ឯកឧត្តម ឆាន់ សាផាន រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សមាជិក

១១- ឯកឧត្តម សយ ស៊ីផុន រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សមាជិក

១២- ឯកឧត្តម ស្វាយ ស៊ីថា រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

១៣- ឯកឧត្តម អ៊ិត ព្រាំង រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សមាជិក

១៤- ឯកឧត្តម ពិត ចំណាន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា សមាជិក

១៥- ឯកឧត្តម សូ ម៉ារ៉ា រដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

១៦- ឯកឧត្តម ឈន អឿម រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា សមាជិក

១៧- ឯកឧត្តម អ៊ុំ មាន រដ្ឋលេខាធិការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

១៨- ឯកឧត្តម ទល់ ទ្បើម ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី សមាជិក

១៩- ឯកឧត្តម យូ ស៊ុនឡុង ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី សមាជិក

២០- ឯកឧត្តម ឈុន ស៊ីរុន អភិបាលខេត្តកណ្តាល សមាជិក

២១- ឯកឧត្តម ជុំ ឈាក់ មេបញ្ជាការរង កងទ័ពជើងគោកនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សមាជិក

២២- ឯកឧត្តម ឃឹល ចន្ទសារា មេធាវីរាជរដ្ឋាភិបាល សមាជិក

២៣- ឯកឧត្តម អង់ តូនីណា សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

២៤- ឯកឧត្តម ឃួន រ៉ានីន អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សមាជិក

២៥- ឯកឧត្តម កែវ សុខសិទ្ធិនី ទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សមាជិក

២៦- ឯកឧត្តម គើត ជឿន ទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សមាជិក

២៧- ឯកឧត្តម សេង សក្ដា អគ្គនាយកក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

២៨- ឯកឧត្តម ប្រាក់ ចាន់ធឿន អគ្គាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សមាជិក

២៩- ឯកឧត្តម ទៀវ សុគន្ធ អគ្គនាយកកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

៣០- លោក សៀង សុខឃុនឌី ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

៣១- លោក សំហេង បុរស ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង និង ជានាយកខុទ្ទកាល័យរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

៣២- អភិបាលខេត្តពាក់ព័ន្ធ សមាជិក

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច :

- តាមដាន ប្រមូលព័ត៌មាន និងលើកវិធានការទប់ស្កាត់ ធ្វើអន្តរាគមន៍ដោះស្រាយតាមផ្លូវច្បាប់នូវរាល់បញ្ហាក្លូដកម្ម បាតុកម្ម ដែលកើតមានឡើងនៅតាមគ្រប់មុខសញ្ញា
- ណែនាំគោលការណ៍ វិធានការដោះស្រាយបាតុកម្ម ក្លូដកម្ម ដល់គ្រប់ក្រសួងស្ថាប័ន រាជធានី និង ខេត្ត
- ធ្វើរបាយការណ៍លើកសំណើអំពីវិធានការដោះស្រាយ និង លទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

ប្រការ ៣ : គណៈកម្មការនេះត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដើម្បីចាត់ចែងការងារប្រចាំថ្ងៃ។

ប្រការ ៤ : សមាជិកនៃគណៈកម្មការទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សម្រាប់សម្រួលការងារ។

ប្រការ ៥ : ថវិកាចំណាយប្រើប្រាស់របស់គណៈកម្មការនេះត្រូវបញ្ចូលបន្ថែមក្នុងខ្ទង់ថវិការបស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា។

ប្រការ ៦ : - នៅថ្នាក់រាជធានី ខេត្ត ត្រូវមានគណៈកម្មការដោះស្រាយកូដកម្ម បាតុកម្ម ប្រចាំរាជធានី ខេត្ត ដែលមានអភិបាលរាជធានី អភិបាលខេត្ត ជាប្រធាន អភិបាលរង ១រូប ជាអនុប្រធាន និងមានមន្ទីរអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធជាសមាជិក។

- នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតគណៈកម្មការដោះស្រាយកូដកម្ម បាតុកម្មតាមការចាំបាច់ ដោយមានអភិបាលក្រុង ស្រុក ខណ្ឌ ជាប្រធាន អភិបាលរងជាអនុប្រធាន និងមានការិយាល័យ អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធជាសមាជិក

- ការបង្កើតគណៈកម្មការដោះស្រាយកូដកម្ម បាតុកម្មរាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយដីការបស់រាជធានី ខេត្ត។

ប្រការ ៧ : សេចក្តីសម្រេចលេខ ៥២ សសរ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មការសម្រាប់ដោះស្រាយកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា និង បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៨ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានី ខេត្ត និងសាមីខ្លួនដែលមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- ឯកសារ - កាលប្បវត្តិ